# សាលាខេត្តកំពង់ឆ្នាំង



# សិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍រវាងខេត្តគោលដៅ
# ស្តីពី
# ភាពជោគជ័យ និងបញ្ហាប្រឈម នៃការអនុវត្តគម្រោងលើកកម្ពស់សិទ្ធិស្ត្រីតាមរយៈការពង្រឹងចំណេះដឹង និងជំនាញរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងឆ្នាំ ២០១៣

## នៅខេត្ត កំពត ក្នុងឆ្នាំ ២០១៤

# មាតិកា

១. សេចក្ដីផ្ដើម

២. សមិទ្ធិផល និងការផ្លាស់ប្ដូរជាវិជ្ជមាន

៣. បញ្ហាប្រឈម

៤. អនុសាសន៍



# ១. សេចក្តីផ្តើម

អនុវត្តតាមអនុស្សរណៈរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងអង្គការ UN- Women ហើយនិងផែនការសកម្មភាពរបស់រដ្ឋបាលខេត្តក្នុងឆ្នាំ២០១៣ គម្រោងនៃអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (Convention on the Elimination of All Forms against Women-CEDAW ស៊ី-ដ បានគាំទ្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងខេត្តសរុបចំនួន <u>**១៧,២០០ ដុល្លា**</u>សហរដ្ឋអាមេរិកក្នុងគោលបំណងលើកកម្ពស់សិទ្ធិស្ត្រីតាមរយៈការពង្រឹងចំណេះដឹង និងជំនាញរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកលើអនុសញ្ញាស៊ី-ដ  ដែលមានរយៈពេល១៨ខែចាប់ផ្តើមពីខែមិថុនា ២០១២រហូតដល់ខែធ្នូ២០១៣។  គម្រោងនេះបានជ្រើសរើសស្ថាប័នគោលដៅចំនួនបីសម្រាប់អនុវត្តជំហានទីមួយរបស់ខ្លួនគឺ ខេត្តកំពង់ឆ្នាំង ស្រុកកំពង់ត្រឡាច និងស្រុករលាប្អៀរ ។

# ២. សមិទ្ធិផល និងការផ្លាស់ប្តូរជាវិជ្ជមាន

១/-បន្ទាប់ពីស្ថាប័នខេត្ត បានបញ្ចូលសេចក្តីត្រូវការរបស់យេនឌ័រក្នុងរបៀបវារៈនៃរបបប្រជុំរបស់គ.ក.ស.ក ក្រុមប្រឹក្សា និងគណៈអភិបាល គោលនយោបាយនៃការដឹកនាំ ការគ្រប់គ្រងនិងអភិវឌ្ឍន៍ស្ថាប័នរបស់រដ្ឋបាលខេត្ត និងមន្ទីរវិស័យត្រូវបានកត់សំគាល់ពីសិទ្ធិស្ត្រី និងជម្រុញឲ្យមានសមភាព និងសមធម៌យេនឌ័រ (សូចនាករកំណត់ហេតុប្រជុំ) និងផ្នែកមួយនៃផែនការអន្តរាគមន៍អភិវឌ្ឍស្ថាប័នរបស់ខេត្តសម្រាប់ឆ្នាំ២០១៤ បានឯកភាពបង្កើតមូលនិធិសមធម៌ (សូចនាករផែនការអន្តរាគមន៍អភិវឌ្ឍស្ថាប័ន) ។

២/-ក្រុមគោលដៅនៃគម្រោងក្នុងខេត្ត(ថ្នាក់ដឹកនាំជាន់ខ្ពស់ អ្នកគ្រប់គ្រងថ្នាក់កណ្តាល និងមន្ត្រី)មានទស្សនវិជ្ជមានចំពោះស្ត្រី (មិនរើសអើង)និងគាំទ្រលើគោលនយោបាយធានាឲ្យមានសមភាព និងសមធម៌យេនឌ័រ ហើយចុះគាំទ្រមូលដ្ឋានដោយភ្ជាប់របៀបវារៈពិភាក្សាសិទ្ធិស្ត្រីជាមូលដ្ឋាន (សូចនាករការសង្កេតវាយតម្លៃវគ្គ និងរបាយការណ៍ចុះមូលដ្ឋាន) ។

៣/-អនុសញ្ញាស៊ីដ និងការតែងតាំងមន្ត្រីសេវាសង្គមសម្រាប់ថ្នាក់ខេត្ត និងក្រុង ស្រុក បានផ្តល់អាទិភាពដល់ស្ត្រីភាគច្រើន

# ២. សមិទ្ធិផល និងការផ្លាស់ប្តូរជាវិជ្ជមាន

៤/- វត្តមានស្ត្រីត្រូវបានលើកកម្ពស់ក្នុងសកម្មភាពអភិវឌ្ឍហើយសូចនាករស្ត្រីត្រូវបាន រំលេចក្នុងរបាយការណ៍នានា ជាពិសេសការតម្លើងឋានៈនាពេលថ្មីក្នុងរចនាសម្ព័ន្ធសាលាខេត្ត (សូចនាករការជ្រើសរើស តែងតាំង បុគ្គលិក របាយការណ៍ គ.ក.ស.ក )

៥/- ស្ត្រីខ្មែរក្នុងខេត្តដែលត្រូវបានគេរំលោភសិទ្ធិនៅបរទេស ត្រូវបានសមត្ថកិច្ចធ្វើអន្តរាគមន៍ឲ្យបានវិលត្រឡប់មករស់នៅក្នុងសង្គមគ្រួសារវិញ និងទទួលបានផលប្រយោជន៍ និងការអប់រំអំពីសុវត្ថិភាពនៃការធ្វើចំណាកស្រុក (សូចនាករកំណត់ហេតុប្រជុំ គ.ក .ស.ក លើកទី២៩ និង៣០)។

# ៣. បញ្ហាប្រឈម

១/-អ្នកសម្របសម្រួលពុំទាន់មានជំនាញសម្របសម្រួល និងចំណេះដឹងសមស្របក្នុងការប្រើប្រាស់វិធីសាស្រ្ត និងបកស្រាយខ្លឹមសារមេរៀនបានពេញលេញ។

២/-អនុសញ្ញាស៊ី-ដ មានលក្ខណៈ ច្បាប់នឹងពាក្យបច្ចេកទេសច្រើនពិបាកយល់ អ្នកសម្របសម្រួល បកស្រាយមិនបានក្បោះក្បាយ។

៣/-ការរៀបចំផែនការសកម្មភាពនិងថវិកាពុំបានផ្តោតលើការឆ្លុះបញ្ចាំងការអនុវត្តសកម្មភាពនៅថ្នាក់រដ្ឋបាលក្រោមជាតិ។

៤/- គម្រោងថវិកាមិនទាន់បានផ្តោតលើការអនុវត្តសកម្មភាពគម្រោងជាមួយអ្នកទទួលផលនៅមូលដ្ឋាននិងវិធិសាស្រ្តប្រមូលទិន្នន័យពាកព័ន្ធមិនទាន់ច្បាស់លាស់។

៥/- គោលនយោបាយជាតិទាក់ទងនិងកាតព្វកិច្ចរបស់រដ្ឋភាគីមាត្រា២-១៦ សេចក្តីណែនាំលំអិត ដែលជាផ្នែកមួយអាចជួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការពន្លឿនសមភាពយេនឌ័រ និងរៀបចំវិធានការបណ្តោះអាសន្ននានាពុំទាន់បានផ្សព្វផ្សាយទូលំទូលាយ

# ៤. អនុសាសន៍

១/- ការអញ្ជើញក្រុមសម្របសម្រួលឬគ្រូឧទ្ទេសគោលដៅសម្រាប់សម្របសម្រួលឬបណ្តុះបណ្តាលបន្តនៅថ្នាក់រដ្ឋបាលក្រោមជាតិ គួរពិនិត្យពីសក្តានុពលដែលអាចជួយធានាក្នុងការផ្ទេរចំណេះដឹងប្រកបដោយប្រសិទ្ធភាពនិងបណ្តុះបណ្តាលអ្នកសម្របសម្រួល។

២/. គួររៀបចំឲ្យមានសន្ទានុក្រមទាក់ទងនឹងពាក្យបច្ចេកទេសទៅនិងអនុសញ្ញាស៊ី-ដ ដើម្បីងាយស្រួលក្នុងការបកស្រាដែលផ្តោតលើការឆ្លុះបញ្ចាំងការអនុវត្តសកម្មភាពនៅថ្នាក់រដ្ឋបាលក្រោមជាតិ។

៣/. គួរបន្ថែមសកម្មភាពនិងថវិកាដែលផ្តោតលើការឆ្លុះបញ្ចាំងការអនុវត្តសកម្មភាព នៅថ្នាក់រដ្ឋបាលក្រោមជាតិ។

៤/- ការរៀបចំថវិកាគម្រោងគួរផ្តោតបន្តទៅដល់ថ្នាក់ឃុំ សង្កាត់ ហើយគម្រោងវិនិយោគគួរកំណត់គោលបំណងជាកលាក់ទាក់ទងនិងការលប់បំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ជាពិសេសទិន្នន័យដើម ។

# ៤. អនុសាសន៍

៥/- សុំឲ្យបន្តនិងពង្រីកវិសាលភាពគម្រោងឲ្យបានច្រើននៅក្នុងខេត្ត ដើម្បីបង្កើនការចូលរួមចំណែក និងផ្សព្វផ្សាយនៃការអនុវត្តសកម្មភាពអនុសញ្ញា ស៊ី-ដ។



# សូមអរគុណ

